**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,
Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធុន សារាយ**
**Mr. THUN Saray**
ជាតំណាងទី ១ និង
ជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
ជាតំណាងទី ២ និង
ជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហិរញ្ញិក
និងជានាយក **CCPCR**

លោក **យៀង វណ្ណា**
**Mr. YEANG Vanna**
ប្រធាន **KKKHRA**

លោក **ជីវ យូម៉េង**
**Mr. CHIV You Meng**
ប្រធាន **KYA**

លោកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep**
នាយិកា **LAC**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
ប្រធាន **PDP Center**

លោក **ទូច ទុម្ព**
**Mr. TOUCH Tum**
នាយក **VIGILANCE**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

នាយិកា **CWCC**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**
**តំណាងយុវជន**

លោក **សិន សែត**
**Mr. SEN Set**
**តំណាងយុវជន**

ស.ប្រ.ក/លេខ ១៤/០៧ គ.ប.ស.យ/អ.ក

*សម្រាប់ការចេញផ្សាយបន្ទាន់*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលនៃការវាយតម្លៃរបស់យុវជននៅលើការបំពេញរបស់រាជរដ្ឋាភិបាលកម្ពុជា ឬ គណបក្សជាប់ឆ្នោតក្នុងការអនុវត្តវិស័យបណ្តុះបណ្តាល និងការបង្កើតការងារ

*មជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន, រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៧*

យុវជនជាម្ចាស់ឆ្នោតមានកម្រិតពេញចិត្តចំពោះការបំពេញការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ឬគណ-បក្សជាប់ឆ្នោតបច្ចុប្បន្ន "តិចតួចបំផុត" ទៅលើការអនុវត្តវិស័យបណ្តុះបណ្តាល និងការបង្កើតការងារ ។

ពិន្ទុជាមធ្យមផ្តល់ឱ្យដោយយុវជនទទួលបាន ២,៨៣ ដែលស្ថិតនៅចន្លោះពី *"កម្រិតមិនពេញចិត្តសោះ" (បង់លេខ ១)* ទៅ *"កម្រិតពេញចិត្តខ្លាំងណាស់" (បង់លេខ ៥)* ។

លទ្ធផលនៃការវាយតម្លៃ បានផ្តោតទៅលើចំណុច ៥ ដូចខាងក្រោម ៖

(១) -ការអនុវត្តគោលនយោបាយសំដៅបង្កើតការងាររបស់រាជរដ្ឋាភិបាល ទទួលបានពិន្ទុ **២,១៩** ។ ពិន្ទុនេះសំដៅទៅក៏រិតពេញចិត្តត្រឹមតិចតួចបំផុត ។

(២) -ការពង្រឹងនូវការអនុវត្តច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានា ដើម្បីធានានូវសិទ្ធិ និងផលប្រយោជន៏របស់កម្មករ និយោជិត និងនិយោជក ទទួលបានពិន្ទុ **២,៣៨ ពោលគឺ "ពេញចិត្តត្រឹមតិចតួចបំផុត"** ។

(៣) -ការបង្កើតបណ្តាញបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្សារភ្ជាប់នឹងមជ្ឈមណ្ឌលសម្រាប់ជួយរកការងារធ្វើឱ្យយុវជន ទទួលបានពិន្ទុ **២,៤៧** ដែលមានកម្រិតពេញចិត្តត្រឹមតិចតួចបំផុត ។

(៤) -ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយពលរដ្ឋវិជ្ជាដល់យុវជន និងការបង្កើតបណ្ណាល័យសាធារណៈ ទទួលបានពិន្ទុ **២,៤៧** សំដៅចំពោះកម្រិតពេញចិត្តត្រឹមតិចតួចបំផុត ។

(៥) -ការពង្រឹងការគ្រប់គ្រងពលករបរទេសនៅកម្ពុជា ក្នុងទិសដៅដោះស្រាយការងារធ្វើ និងស្រូបយកបច្ចេកវិទ្យាថ្មី ត្រូវបានផ្តល់ពិន្ទុចំនួន **២,៣១** សំដៅចំពោះកម្រិតពេញចិត្តត្រឹមតិចតួចបំផុត ។

ការវាយតម្លៃដោយការផ្តល់ជាពិន្ទុនេះត្រូវបានធ្វើឡើងនៅឯ**"វេទិកាសំឡេងម្ចាស់ឆ្នោតយុវជន"** ដែលផ្តោតលើប្រធានបទស្តីពីលទ្ធផលសម្រេចបានរបស់មន្ត្រី និងគណបក្សជាប់ឆ្នោត *"លើការបណ្តុះបណ្តាល និងការបង្កើតការងារសម្រាប់យុវជន"* នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៧ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-

ជប៉ុន រាជធានីភ្នំពេញ ដែលរៀបចំឡើង **ខុមហ្វ្រែល** សហការជាមួយក្រុមប្រឹក្សាយុវជនកម្ពុជា សមាគមយុវជនខ្មែរ និងកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន ជាមួយនឹងការពិភាក្សាយោបល់និងស្តាប់របាយការណ៍ជាក់ស្តែងរបស់វាគ្មិន ជាអ្នកតំណាងរាស្ត្រ អ្នកជំនាញការ ប្រធានសមាគម និងតំណាងក្រសួងការងារទាក់ទិននឹងការអនុវត្តវិស័យបណ្តុះបណ្តាល និងការបង្កើតការងារ។

វេទិកានេះជាផ្នែកមួយនៃ **"កម្មវិធីឃ្លាំមើលរាជរដ្ឋាភិបាល"** របស់គណៈកម្មាធិការខុមហ្វ្រែល និងជាសំខាន់ប្រធានបទខាងលើនេះ គឺជាបញ្ហាដែលកំពុងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅ និងអនាគត របស់ម្ចាស់ឆ្នោត។

កំណើនប្រជាជនដែលគ្រប់អាយុអាចចូលបំរើការងារមានប្រហែលចន្លោះពី ៣០ ម៉ឺននាក់ ទៅ ៣៥ ម៉ឺននាក់ ប៉ុន្តែ ការពិភាក្សារកឃើញថា មានចំនួនយុវជនតិចតួចប្រមាណពី ៥០.០០០ ទៅ ៦០.០០០ នាក់ប៉ុណ្ណោះ បានការងារធ្វើក្នុងមួយឆ្នាំៗ...

*សម្រាប់របាយការណ៍លម្អិតស្តីពីការវាយតម្លៃនេះ សូមមើលការចេញផ្សាយរបាយការណ៍ជូនភ្ជាប់មកជាមួយ។*

គណៈកម្មាធិការ**ខុមហ្វ្រែល** នឹងរៀបចំវេទិកានេះជាបន្តទៀតដោយផ្តោតលើប្រធានបទថ្មីៗផ្សេងទៀត ពាក់ព័ន្ធនឹងកម្មវិធីនយោបាយរាជរដ្ឋាភិបាលក្នុងពេលឆាប់ៗនេះ។


*សម្រាប់ព័ត៌មានលម្អិតសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ក្មុយ ច័ន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១